សុន្ទរកថារបស់ **លោក តាម៉ាមីស៊ឺ ស៊ីនីជិ**

លេខាទីមួយ ប្រធានផ្នែកសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា

ថ្លែងក្នុងពិធីសម្ពោធអគារព្យាបាលជំងឺទូទៅក្នុងមន្ទីរពេទ្យបង្អែកពារាំង ខេត្តព្រៃវែង

១៨ កញ្ញា ២០១៣

**សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ!**
**សូមគោរព ឯកឧត្ដម អេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាល!**
**សូមគោរព លោក សុទ្ធ សឺន អភិបាលរងខេត្តព្រៃវែង!**
**សូមគោរព លោក វេជ្ជបណ្ឌិត សេង បញ្ញារិទ្ធ ប្រធានមន្ទីរសុខាភិបាលខេត្ត!**
**សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្ដីសោមនស្សរីករាយដើម្បីចូលរួមក្នុងពិធីសម្ពោធអគារព្យាបាលជំងឺទូទៅក្នុងមន្ទីរពេទ្យបង្អែកពារាំង ជាមួយវត្តមានរបស់ឯកឧត្ដម អេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាល។

ខ្ញុំមានសេចក្ដីសោមនស្សរីករាយក្រៃលែងដែលពិធីនេះត្រូវបានប្រារព្ធធ្វើឡើងក្នុងឱកាសដ៏ពិសេសនៃឆ្នាំ២០១៣នេះដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

ជាបឋម ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលខេត្តព្រៃវែងដែលបានរៀបចំឲ្យមានពិធីនេះឡើង។

ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះបន្ទាប់ពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងកិច្ចកសាង និងអភិវឌ្ឍន៍ប្រទេសឡើងវិញរហូតបានក្លាយជាប្រទេសមួយដែលមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងចំណោមបណ្ដាប្រទេសដែលមានសេដ្ឋកិច្ចរីកចំរើនក្នុងតំបន់អាស៊ាន។ ជាមួយគ្នានេះផងដែរ វិស័យសុខាភិបាលបានរីកចំរើនយ៉ាងខ្លាំងទាំងបរិមាណ និងគុណភាពក្រោមកិច្ចសហការរវាងក្រសួងសុខាភិបាល និងសហគមន៍អន្តរជាតិ។

រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្ដល់ការឧបត្ថម្ភគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈគម្រោងជាច្រើនរួមមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ការផ្ដល់សម្ភារៈសុខាភិបាល ព្រមទាំងការបណ្ដុះបណ្ដាលបុគ្គលិកសុខាភិបាល និងបុគ្គលិកបច្ចេកទេសជាដើម។

ទោះជាយ៉ាងណាក៏ដោយ នៅតែមានតម្រូវការខ្ពស់សម្រាប់ការកែលម្អសេវាសុខាភិបាលសាធារណៈ។ ហើយបញ្ហាចម្បងមួយក្នុងចំណោមបញ្ហាជាច្រើននោះគឺកង្វះហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលនិងសម្ភារៈបរិក្ខាពេទ្យចាំបាច់នៅតំបន់ជនបទដាច់ស្រយាល។ ជាក់ស្តែងអ្នកជំងឺមួយចំនួនត្រូវសម្រាកនៅតាមផ្លូវដើរក្នុងមន្ទីរពេទ្យដោយសារកង្វះបន្ទប់អ្នកជំងឺ។

ខ្ញុំបានទទួលដំណឹងថាចំនួនអ្នកជំងឺនៅមន្ទីរពេទ្យបង្អែកពារាំងបានកើនឡើងយ៉ាងរហ័សក្នុងប៉ុន្មានឆ្នាំនេះ ហើយជាបញ្ហានោះគឺថា ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ក្នុងមន្ទីរពេទ្យមិនអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនក្នុងតំបន់បានទេ។ អគារជំងឺទូទៅថ្មីដែលឧបត្ថម្ភដោយជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចរបស់ជប៉ុននេះ នឹងអនុញ្ញាតិឲ្យអ្នកជំងឺកាន់តែច្រើនអាចទទួលបានការព្យាបាលជំងឺប្រកបដោយសុវត្ថិភាព និងក្នុងបរិស្ថានការយកចិត្តទុកដាក់បំផុតដែលសង្ឃឹមថានឹងជួយរួមចំណែកលើកស្ទួយសុខុមាលភាពរបស់ប្រជាជននៅក្នុងតំបន់។

ខ្ញុំបានដឹងថា អង្គការបេះដូងជប៉ុនដែលជាអង្គការក្រៅរដ្ឋាភិបាលមួយរបស់ជប៉ុនបាននិងកំពុងជួយដល់ផ្នែកវះកាត់នៅក្នុងមន្ទីរពេទ្យនេះអស់រយៈពេលបួនឆ្នាំមកហើយ ហើយយើងសង្ឃឹមថាការរួមបញ្ចូលគ្នានៃសកម្មភាពទាំងនេះអាចផ្តល់ប្រសិទ្ធភាពកាន់តែប្រសើរឡើង។

ជាចុងក្រោយនេះ ក្នុងនាមរដ្ឋាភិបាល និងប្រជាជនជប៉ុន  ខ្ញុំសង្ឃឹមថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!